ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សាលក្រមព្រហ្មទណ្ឌ

លេខ: ៥៤ "ឈ"/៥៧០

ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ: ១០៥០

ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

-សំណុំរឿងស៊ើបសួរ: ១១៤២

ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ: ៤២៥

ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ១៤ និង០០នាទី នៅសាលសវនាការ (ខ ១) ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១០៥០ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុគា ភេទស្រី កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨០ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប មុខរបរបុគ្គលិកអនាម័យមន្ទីពេទ្យគន្ធបុប្ផាខេត្តសៀមរាប ម៉េមាយ មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted] មុំ (រស់) ម្ដាយឈ្មោះ [redacted] លី (រស់) ទោសពីមុនគ្មាន ជានីតិជន។ (ក្រៅឃុំ)

ពីបទ: "ឆបោក" ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញាត្តិ និងចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧ និង មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។ (អវត្តមាន)

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។ (វត្តមាន)

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថា។ (វត្តមាន)

### <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ នៅចំណុចទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] សុគា បាននិយាយលួងលោមឈ្មោះ [redacted] ថា សុំបង្វិលប្រាក់ចំនួន ៥,៤០០ (ប្រាំពាន់បួនរយ)

ដុល្លារអាមេរិក ក្នុងរយៈពេល ០១ខែ ដោយសន្យាសងប្រាក់ទៅឲ្យឈ្មោះ ចាន់ ថា វិញចំនួន ៥,៦៥០ (ប្រាំពាន់ប្រាំមួយរយហាសិប)ដុល្លារអាមេរិក។ នៅពេលមកសុំបង្វិលប្រាក់ពីឈ្មោះ [redacted] ថា ឈ្មោះ [redacted] សុគា បានយកកាតអេធីអឹម និងសៀវភៅធនាគារ(ធនាគារកម្ពុជាពាណិជ្ជ) ដែលជារបស់ខ្លួនមកប្រគល់ឲ្យឈ្មោះ [redacted] ថា ដើម្បីធានាលើការសុំបង្វិលប្រាក់ខាងលើ ធ្វើឲ្យឈ្មោះ [redacted] ថា មានការជឿជាក់ និងព្រមប្រគល់ប្រាក់ឲ្យទៅឈ្មោះ [redacted] សុគា ចំនួន ៥,៤០០ (ប្រាំពាន់បួនរយ)ដុល្លារអាមេរិក។ លុះដល់កាលកំណត់ដែលឈ្មោះ [redacted] សុគា ត្រូវសងប្រាក់ឲ្យទៅឈ្មោះ [redacted] ថា ស្រាប់តែឈ្មោះ [redacted] សុគា បែរជាគេចវេសមិនព្រមសង និងបានរត់គេចខ្លួនបាត់។ ក្រោយពីមិនព្រមសងប្រាក់ឈ្មោះ [redacted] ថា បានយកកាត និងសៀវភៅរបស់ឈ្មោះ [redacted] សុគា ទៅដកប្រាក់ស្រាប់តែគណនីរបស់ឈ្មោះ [redacted] សុគា ត្រូវបានបិទ ចំណែកឈ្មោះ [redacted] សុគា បានគេចវេសមិនព្រមសងប្រាក់ទៅឈ្មោះ [redacted] ថា រហូតដល់បច្ចុប្បន្ន។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១២១៩ អ/យ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៤/អយ.អ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៦៨ ពស.ព្រស/អ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១។

## នាពេលសវនាការ

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុគា បានឆ្លើយបញ្ជាក់ថា៖ កាលពីអំឡុងឆ្នាំ២០១៦ ខ្លួនបានខ្ចីចងការប្រាក់ពីឈ្មោះ [redacted] ថា ចំនួន ៣,០០០ (បីពាន់)ដុល្លារអាមេរិក ដោយគិតការប្រាក់ ៥% (ប្រាំភាគរយ) ក្នុងមួយខែ ហើយខ្លួនបានដាក់បញ្ចាំកាត ATM ដើម្បីឲ្យឈ្មោះ [redacted] ថា បើកការប្រាក់រយៈពេល ០៤ឆ្នាំមកហើយ ទើបសងគ្រប់ចំនួន ក្រោយមកទៀតក្នុងខែឧសភា ឆ្នាំ២០២០ ខ្លួនបានខ្ចីប្រាក់សរុបទាំងអស់ ៧,០០០ (ប្រាំពីរពាន់)ដុល្លារអាមេរិក ដោយដាក់បញ្ចាំកាត ATM សៀវភៅបញ្ជីធនាគារ ដោយគិតការប្រាក់ចំនួន ៣០០ (បីរយ)ដុល្លារអាមេរិក ក្នុងមួយខែ ខ្លួនបានបង់ការប្រាក់ចំនួន ០៥ខែ គិតពីខែមិថុនា ដល់ខែវិច្ឆិកា ទើកតែខកខានចាប់ពីខែធ្នូ ឆ្នាំ២០២០ ដោយមូលហេតុកន្លែងធ្វើការខាងមន្ទីរពេទ្យគន្ធបុប្ផាបានបញ្ឈប់ខ្លួនពីការងារដោយបញ្ហាកូវីដ១៩។ ខ្លួនស្នើសុំតុលាការឲ្យដោះលែងខ្លួនឲ្យមានសេរីភាពបានត្រឡប់ទៅផ្ទះវិញ ដោយហេតុថាខ្លួនបានខ្ចីប្រាក់ឈ្មោះ [redacted] ថា ប្រាកដមែន ហើយខ្លួនក៏មានឆន្ទះក្នុងការសងវិញឲ្យគ្រប់ចំនួនដែរ ម្យ៉ាងទៀតមិនមានចេតនា ក្នុងការគេចវេសការកោះហៅឲ្យចូលខ្លួនពីតុលាការនោះទេ។ ខ្លួនសូមសន្យាថានឹងរកប្រាក់សងឈ្មោះ [redacted] ថា វិញ ឲ្យគ្រប់ចំនួន និងសន្យាចូលមកបង្ហាញខ្លួននៅតុលាការនៅគ្រប់ដំណាក់កាលដែលតុលាបានកោះហៅនាងខ្ញុំ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន: ជនជាប់ចោទពិតជាបានធ្វើកិច្ចសន្យាខ្ចី និងមានឯកសារបញ្ចាំដូចជា កាត ATM (ប្រាក់បៀវត្ស) ពីកូនក្តីរបស់ខ្លួនពិតមែន តែជនជាប់ចោទបានប្តូរ កាត ATM (ប្រាក់បៀវត្ស) ថ្មី ហើយមិនបានប្រាប់កូនក្តីខ្លួន បណ្តាលឲ្យកូនក្តីរបស់ខ្លួនមិនអាចដកប្រាក់បាន។ ហើយម្យ៉ាងទៀតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ រយៈពេល ០៥ខែ ចាប់ពីអំឡុងខែមិថុនា ដល់ខែវិច្ឆិកា ឆ្នាំ២០២០ ជនជាប់ចោទមិនបានបន្តសងប្រាក់កូនក្តីរបស់ខ្លួនទៀត នេះជាបទល្មើស ម្យ៉ាងវិញទៀតជនជាប់ចោទមិនបានតម្កល់ប្រាក់ តាមចៅក្រមស៊ើបសួរ និងពុំមានអាសយដ្ឋានច្បាស់លាស់។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន: ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការរួចមកយល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] សុគា មានឆន្ទះក្នុងការសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីវិញហើយ ម្យ៉ាង

វិញទៀតជនជាប់ចោទមានអាសយដ្ឋានច្បាស់លាស់ដែរ ឃើញថាជនជាប់ចោទបានសារភាព និងទទួលស្គាល់ទោសកំហុសរបស់ខ្លួនរួចហើយ តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ទុកបានការដដែល និងសុំឱ្យចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់។

-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ កូនក្តីខ្លួនបានធ្វើកិច្ចសន្យាខ្ចីបរិភោគ ដោយមានការប្រាក់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដោយមានកិច្ចសន្យាត្រឹមត្រូវប្រាកដមែន ហើយកូនក្តីខ្លួនបានសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីវិញជាបន្តបន្ទាប់តាមការកំណត់ហើយដែរ។ ព្រោះកូនក្តីរបស់ខ្លួនបានបញ្ជាក់ថា ខ្លួនមានឆន្ទះក្នុងការសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីវិញឱ្យគ្រប់ចំនួនផងដែរ។

## សំអាងហេតុ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយចុងក្រោយរបស់ជនជាប់ចោទ សុំតុលាការជួយដោះលែងដើម្បីរកលុយសងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ថា វិញ ខ្លួនដឹងខុសហើយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សាលាដំបូងខេត្តសៀមរាប

## យល់ឃើញថា

១.កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ នៅចំណុចភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឈ្មោះ [redacted] សុគា បាននិយាយលួងលោមឈ្មោះ [redacted] ថា សុំបង្វិលប្រាក់ចំនួន ៥,៤០០ (ប្រាំពាន់បួនរយ) ដុល្លារអាមេរិក ដោយបានដាក់កាត ATM និងសៀវភៅធនាគារ(ធនាគារកម្ពុជាពាណិជ្ជ) ជាមួយឈ្មោះ [redacted] ថា បានសន្យាថា សុំបង្វិលត្រឹមតែ០១ខែតែប៉ុណ្ណោះ បន្ទាប់ឈ្មោះ [redacted] សុគា សុំខ្ចីប្រាក់ពីឈ្មោះ [redacted] ថា ថែមទៀត ដោយសន្យាថានិងសងប្រាក់ទៅឈ្មោះ [redacted] ថា ទាំងការទាំងដើមចំនួន ៧,០០០ (ប្រាំពីរពាន់)ដុល្លារអាមេរិកវិញ ដូច្នេះស្ថិតនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ពិតជាមានបទល្មើស ឆបោក ដែលប្រព្រឹត្តឡើងដោយជនជាប់ឈ្មោះ [redacted] សុគា ពិតប្រាកដមែន ។

២.យល់ឃើញថា តាមចម្លើយសារភាពរបសជនជាប់ចោទ បានឆ្លើយបញ្ជាក់ថា៖ នៅថ្ងៃ០១ ខែឧសភា ឆ្នាំ២០២០ ស្ថិតនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដោយខ្លួនបានយកកាត ATM និងសៀវភៅធនាគារ (កម្ពុជាពាណិជ្ជ) របស់ខ្លួនទៅដាក់បញ្ចាំ(ធ្វើកិច្ចសន្យាខ្ចីបរិភោគ)ជាមួយដើមបណ្តឹងរដ្ឋប្បវេណីពិតមែន ហើយសន្យាថាសុំបង្វិលតែ១ខែតែប៉ុណ្ណោះ ដូច្នេះពិតជាមានភាពស៊ីសង្វាក់គ្នាជាមួយអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើ ឆបោក ទៅលើដើមបណ្តឹងរដ្ឋប្បវេណី ប្រាកដមែន គប្បីតុលាការពិចារណា និងសម្រេចផ្តន្ទាទោសតាមផ្លូវច្បាប់។

៣.តាមការប្តឹងសុំចោទប្រកាន់របស់តំណាងអយ្យការ គឺវាមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុពិតជាក់ស្តែងដែលអាចអោយតុលាការជឿជាក់ថា ពិតជាមានបទល្មើស ឆបោក ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក



Scanned with CamScanner

ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិ និងចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៤.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៦៨ ពស.ព្រស/ដ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុគា ជំនុំជម្រះពីបទ ឆបោក ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិ និងចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៥.ជនជាប់ចោទឈ្មោះ [redacted] សុគា មាននីតិសម្បទាគ្រប់គ្រាន់ និងស្ថិតក្នុងវ័យដែលអាចដឹងខុសត្រូវបាន ហើយរាល់អំពើរបស់ជនជាប់ចោទខាងលើនេះ សុទ្ធតែឆ្លងកាត់នូវការគិតពិចារណាជាមុន ដូច្នេះអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺមានចេតនាទុច្ចរិតពិតប្រាកដមែន ។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទខាងលើបានបង្ក ឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។

៦.មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សុគា ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិ និងចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សាលាដំបូងខេត្តសៀមរាប

## សម្រេច

១.ផ្តន្ទាទោសឈ្មោះ [redacted] សុគា ភេទស្រី កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨០ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៦ (ប្រាំមួយ)ខែ។

ពីបទៈ "ឆបោក" ប្រព្រឹត្តនៅភូមិទក្សិណត្បូង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិ និងចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យឈ្មោះ [redacted] សុគា ភេទស្រី កើតថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៨០ ជនជាតិខ្មែរ សងសំណង ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ សរុប ៧,០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាធារណៈនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុគា ទុកសិទ្ធឲ្យប្តឹងឧទ្ធរណ៍ តាមនីតិវិធី និងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**

[redacted] [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃអង្គារ១រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប,ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner